Sacombank

# TERMS AND CONDITIONS FOR THE ISSUANCE AND USE OF DEBIT CARDS ISSUED BY SACOMBANK (CAMBODIA) PLC. TO CARDHOLDERS

Effective from 01/07/2014

## 1. GENERAL ACKNOWLEDGEMENT

The content of these Terms and Conditions together with the Application and Agreement constitutes the contract between Sacombank (Cambodia) Plc. and the Cardholder. In entering into the contract, evidenced by the signing of the Application and Agreement, Sacombank Cambodia and the Cardholder bind themselves to comply with these Terms and Conditions governing the issuance and use of Sacombank Cambodia Debit Card (hereafter named "Card"). The Cardholder is responsible for reading carefully and considering these Terms and Conditions before using the Card.

## 2. EXPLANATION OF TERMS

2.1. "Sacombank Cambodia" means Saigon Thuong Tin Bank Cambodia Plc.

2.2. "Card" means the debit card issued by Sacombank Cambodia to the Cardholder to conduct Transactions on the Card Account, including any renewal or replacement Card thereof.

2.3. "Cardholder" means the person to whom a Card is issued by the Bank. Cardholder includes the Primary Cardholder and/or the Supplementary Cardholder.

2.4. "Primary Cardholder" means the person who applies for a Card and is responsible and liable for all Card Transactions, fees and charges relating to the Card (including the use of Supplementary Card)

2.5. "Supplementary Cardholder" means the person to whom the Card is issued by the Bank at the Primary Cardholder's request and it is proved through the Cardholders signature on the Sacombank Cambodia Debit Card Application and Agreement.

2.6. "Sacombank Cambodia Debit Card Application and Agreement" (hereafter named "Service Application Form") means the form issued by Sacombank Cambodia and signed by the Cardholder in order to request Sacombank Cambodia to consider issuing the Card.

2.7. "ATM" means an automated teller machine or a card operated machine belonging to Sacombank Cambodia or any other organisation which is authorised to accept the Card and allows the Cardholder to conduct certain Card Transactions.

2.8. "Card number" means the 16 digits number printed on the Card. The Cardholder can use the Card number to execute any Card transaction.

2.9. "Card Account" or "Card Account number" (Account number) means the 12 digits number printed on the Card or on the letter attached with the Card. Account number is also the Principal Cardholder's designated savings account held with Sacombank Cambodia through which Transactions are settled.

2.10. "Card Transaction" means any payment made or any amount charged for any goods, services, cash withdrawal, transfer or deposit of funds and/or any other transactions made, through the use of the Card at ATMs or Card Accepting Agents whether conducted with PIN and/or OTP and/or signature or otherwise.

2.11. "Online Card Transaction" means any payment made or any amount charged for any goods, services on the website of Card Accepting Agents.

2.12. Card Accepting Agents: (hereafter named Agent) means any organisation or individual which is authorised to accept the Card and allows the Cardholder to make certain Card Transactions.

2.13. "PIN" or "Personal Identification Number" means the code of numbers and/or characters issued by Sacombank Cambodia to a Cardholder, or selected (where available) by the Cardholder in relation to a Card required to make certain Card Transactions at ATM or POS.

2.14. "OTP": (one time password) mean the code of numbers issued by Sacombank Cambodia to a Cardholder via an authentication device (SMS, token…), which is required to approve for Online Card Transaction

2.15. "POS" means a device used by an Agent to make certain Card Transactions.

## 3. PROTECTION OF CARD – PIN – OTP

3.1. The Card is the exclusive property of Sacombank Cambodia at any times. The Cardholder shall not transfer the Card and shall maintain control and custody of the Card at all times

3.2. Only the Cardholder may use his/her Card, PIN and/or OTP, where required to make Card Transactions.

3.3. PIN and/or OTP issued by Sacombank Cambodia to the Cardholder for use of the Card must be non-transferable and strictly confidential and shall not disclose to any other person whether voluntary or not. Any usage of Card conducted with the PIN and/or OTP whether made by the Cardholder or any other person, shall be considered to be used by the Cardholder. Cardholder must be responsible for carrying out any obligation and incurring any consequence arising from those transactions.

3.4. The Cardholder shall not use the Card or allow any other persons to use the Card and must be returned the card(s) in cut a half right after happening one of the following circumstances (a) the Card was replaced or damaged; (b) the use of the Card was terminated in accordance with the provisions of the Terms and Conditions; (c) the Cardholder was found out the Card after the Card had been reported to be lost or stolen; (d) the validity period noted on the Card (if any) expires.

Any behaviour using the Card after happening the above circumstances shall be considered to be illegal. The Cardholder must be compensated Sacombank Cambodia for any loss damage, as the Cardholder fails to exactly comply with the provision of this clause.

## 4. ACCOUNT AND CARD TRANSACTIONS

4.1. The Cardholder irrevocably and unconditionally, authorises Sacombank Cambodia to debit or credit, deduct, set aside the Card Account or any other accounts of the Cardholder opened with Sacombank Cambodia (if the Card Account balance is not enough for payment of the Cardholder's financial obligations to Sacombank Cambodia) without the Cardholder's announcement, request confirmation and approval to reclaim all the due debts that the Cardholder must pay under the provisions of the Contract, including financial obligations relating to the use of the Card terminated and/or Card Account clocked.

4.2. If the Cardholder uses the Card, PIN and/or OTP to make a reservation or reserve a priority right in any transaction with an Agent, and after that not using the services of such Agent, the Cardholder shall solely be liable if such Agent charges an amount for making such reservation or reserving the priority right for in accordance with the provisions of the Agent.

4.3. Sacombank Cambodia has the right to debit the Card Account for the value of transactions affected by using the Card not with standing any non-delivery, defect and/or non-performance of any goods or services, and the Cardholder shall be solely responsible for claiming to or solving any dispute with the applicable ATM provider or Agent regarding such claim or dispute.

4.4. Any transactions, fees or charges which are denominated in a currency different to the currency of the Card Account will be automatically converted into the currency of the Card Account immediately at the point of using and a fee rate determined at Sacombank Cambodia's absolute discretion shall be debit to the Card Account.

4.5. The Cardholder must ensure the balance of the Card Account must be enough to settle any transactions, fees or charges in relation to the Card. In any event Sacombank Cambodia may, at its absolute discretion, carry out without having to inform prior to or present any reason to the Cardholder as follow:

a) Approves, authorises or allows any transaction, fee or charge which the Cardholder must be incurred even though the balance of the Card Account is not enough funds; or

b) Refuses to approve, authorise and/or permit to be effected any Transaction, fee or charge even though there are sufficient funds in the Account.

4.6. Where a transaction, fee or charge is proposed to be effected, Sacombank Cambodia may hold and/or set aside funds of the Card Account of an amount estimated at Sacombank Cambodia's sole discretion for the value of any Card Transaction proposed to make. Such amount may be held, set aside and/or released at Sacombank Cambodia's sole discretion and may not be the exact amount of the transaction, fee or charge which is finally debited to the Card Account.

4.7. The Cardholder may not be able to execute some transactions according to the regulations of Sacombank Cambodia in each period.

## 5. CARDHOLDER'S COMMITMENTS

5.1. The Cardholder must sign the Card immediately upon receiving the Card.

5.2. The Cardholder commits to present his/her authenticated personal documents and, accurately, completely and punctually provide all necessary information at the Sacombank Cambodia's request for carrying out the Card Transactions, checking data, settling disputes/claims relating to the Card Transactions. Information transferred from the Cardholder to Sacombank Cambodia via email or telephone is unacceptable.

5.3. The Cardholder undertakes not to make or allow any person to make a Card Transaction for illegal purposes or in contrast to conventional use of the Card.

5.4. In case the Cardholder makes a Card Transaction with the value that overdraws the Card Account balance at the point of making the Card Transaction, the Cardholder must immediately refund the overdrawn amount whether the Cardholder receives Sacombank Cambodia's announcement/request or not and pay the overdrew amount's interest which is equal to 150% of Sacombank Cambodia credit card interest at the point of overdrawing (interest shall be accumulated from the date the Card Account balance is overdrawn to the date the overdrew amount is fully refunded).

## 6. CARDHOLDER'S RIGHTS AND LIABILITIES

6.1. In the event that the Card is lost, stolen, damaged or PIN and/or OTP is disclosed:

a) The Cardholder must notify Sacombank Cambodia via telephone immediately and Cardholder must officially visit Sacombank Cambodia to confirm such notification in writing or sent lawful data message to Sacombank Cambodia within 12 hours from the point of making the notification.

b) The Cardholder may request Sacombank Cambodia to issue a replacement Card and/or PIN.

6.2. The Cardholder continues to be liable for all the Card Transactions (including any damage, lost arising from the Card Transactions) made before the Cardholder's written notice on the Card lost, stolen, damaged or PIN and/or OTP disclosed, is certified by Sacombank Cambodia whether such Card Transaction is authorised by the Cardholder or not.

6.3. The Cardholder shall hereby indemnify Sacombank Cambodia for any loss or damage suffered by Sacombank Cambodia in connection with or arising from the issuance or use of the Card or PIN and/or OTP.

6.4. The Cardholder must immediately notify Sacombank Cambodia in writing of (a) any changes to Cardholder information, including any changes in his/her address and/or other contact details; and/or (b) any other information that Sacombank Cambodia may request from time to time.

6.5. The Cardholder must comply with the application procedure, transaction process and other guidelines from Sacombank Cambodia.

6.6. The Cardholder must bear all damage (if any) to the Card Transaction, arising from the Cardholder's mistake, neglect or the Card Transaction is abused by another person.

6.7. The Cardholder could request for charge back of any incorrect Card Transaction arising from Sacombank Cambodia's mistake within 60 days from the date a Card Transactions is made, through the use of the Card at ATMs, POS or online. After this date, the Cardholder's request will not be considered.

## 7. SACOMBANK CAMBODIA'S RIGHTS AND LIABILITIES

7.1. Sacombank Cambodia may, at any time, at its sole discretion and without prior notice or without presenting reason to the Cardholder, have the right to: (i) supplement, amend the expiry date and/or other details of the issued Card, replace the Card; (ii) request the Cardholder to change PIN set by the Cardholder; (iii) restrict, suspend or terminate the use of any Card, any services and/or facilities relating to the Card and/or the Card Transaction.

7.2. Sacombank Cambodia has the right (but no obligation) to implement necessary methods, including preventing or rejecting the Card Transaction, without informing the Cardholder in advance in the following cases

a) Account transaction is not made by the Cardholder;

b) In order to prevent money laundering in compliance with the laws;

c) The Cardholder's account balance at Sacombank Cambodia is claimed. The claim must be based on legal reasons
d) Complying with the competent authority's request;
e) Preventing any damage to Sacombank Cambodia and/or Cardholder.
f) The transaction is illegal or against the convention of card usage.

Sacombank Cambodia shall inform the Cardholder after the above methods made.

7.3. Immediately upon receiving the Cardholder's notification under the provision of Clause 6.1 a), Sacombank Cambodia will pause the card usage of the Cardholder until the Cardholder directly visits Sacombank Cambodia to request for the continuation the card usage and/or until the Cardholder receives a replacement card.

7.4. Sacombank Cambodia shall not be responsible for indemnifying damage arising from the card usage to withdraw money at ATM, includes but not limited to the failure of not receiving or not receiving the full amount withdrew.

## 8. FEES

8.1. Sacombank Cambodia has the right to charge and debit the Account for the following fees:
a) Issuing fee: charged upon issuance and/or renewal of the Card
b) Fast issuing fee: charged when the Cardholder requests the expedited issuance or replacement of the Card.
c) Statement fee: charged when a statement of transactions is sent to the Cardholder
d) Annual fee: charged for each Card once per year or divided into twelve (12) equal amounts and charged monthly.
e) Cash advance fee: charged upon use of the Card to withdraw cash.
f) Balance inquiry fee: charged upon use of the Card to obtain the Account balance
g) Card replacement fee: charged when the Cardholder requests a replacement Card.
h) Lost or stolen Card fee: charged when the Cardholder notifies Sacombank Cambodia of a lost or stolen Card.
i) PIN reissue fee: charged when the Cardholder requests the PIN to be reissued.
j) Confirmation fee: charged when the Cardholder requests Sacombank Cambodia to confirm in writing information related to the Card, Transaction or Account.
k) Copy of Transaction receipt fee: charged when the Cardholder requests a copy of the original Transaction receipt.
l) Incorrect chargeback request fee: charged when the Cardholder's chargeback request is found to be wrong or inaccurate.
m) Forex marked up fee: charged on the conversion of foreign currency amounts into the currency of the Account.
n) Exception request fee: charged when the Cardholder requests an additional or special work request to be undertaken by Sacombank Cambodia.
o) Product change fee: charged when the Cardholder requests a change to a different type of debit card product or the addition or removal of a service, benefit or feature.
p) Debit dishonour fee: charged when a debit to the Account is dishonoured due to lack of cleared funds in the Account.

8.2. The details of the above fees are set out in Sacombank Cambodia's schedule of fees (the "Fee Schedule") to be applicable to the Card and this Fee Schedule is an integral part of the Terms and Conditions. In the event of change of fee rate, kind of fee and model of fee payment, the Cardholder will be noticed in accordance with Article 11. The new fee schedule will be bound to the Cardholder if the Cardholder continues to use the service as of the date the new Fee Schedule took effect. The current Fee Schedule can be accessed at www.sacombank.com.kh or at any branch of Sacombank Cambodia or by calling the Customer Services Centre of Sacombank Cambodia.

## 9. TERMINATION OF CARD

9.1. Each party has the right to unilaterally terminate the use of the Card contract by notifying 10 (ten) days in advance to the other party in writing. The Principal Cardholder may unilaterally terminate any Supplementary Cardholder's use of Card. The termination of the Principal Card means the termination of the contract. If Sacombank Cambodia unilaterally terminates the card usage due to complying with the competent authority's request or the Cardholder violent his/her obligation, undertaken to Sacombank Cambodia, Sacombank Cambodia shall have no liability to inform the Cardholder in advance.

9.2. After the termination of the card usage is effected: (a) the Cardholder shall

continuously be responsible for paying up all transactions, fees, expenditures, charges, penalty and any compensation made before or after terminating the use of the Card (including fees and expenditures not being debited on the Card Account); (b) all the undue payments under this Contract will become due and must be paid immediately without notification or request; (c) Sacombank Cambodia, therefore, will not be responsible for reimbursing any fee; (d) and, the Contract and its Terms and Conditions remain valid until the Cardholder completely and fully finishes his/her financial obligations to Sacombank Cambodia.

9.3. After terminating the card usage and the Cardholder finishes his/her financial obligations to Sacombank Cambodia, if the Card Account still exists balance and the Cardholder does not come to Sacombank Cambodia to receive such amount, Sacombank Cambodia will have the right to charge the management fee over such amount under Sacombank Cambodia's regulations from time to time.

## 10. AUTHENTICITY OF DOCUMENTS

10.1. Sacombank Cambodia may rely upon (a) any document relating to a Transaction, request and/or instruction signed by the Cardholder; (b) any transaction using the PIN and/or OTP of the Cardholder (c) or any other records available to Sacombank Cambodia, including verbal and electronic instructions relating to the Cardholder, Card Account or the use of the Card; as authentic evidence proving that the Card Transaction, request and/or instructions are made by the Cardholder.

10.2. The Cardholder must, in writing, advise Sacombank Cambodia any omission, error and/or query relating to any Card Transaction, fee, debit and/or credits charged to the Card Account within ten (10) days from the date of happening such omission, error and/or query. During this period, if Sacombank Cambodia does not receive any claim from the Cardholder, the amount charged to the Card Account will be the authentic evidence proving that the transaction, fees, debits and/or credits are exact and valid unless Sacombank Cambodia may, at its sole discretion, decide to amend and/or supplement the charges to the Account at any later time.

## 11. NOTICES AND COMMUNICATIONS

11.1. All Sacombank Cambodia's announcements to the Cardholder will be sent in writing to the latest address registered by the Cardholder or posted on Sacombank Cambodia's official website or announced on the media or posted through Sacombank Cambodia network. All the announcements shall be considered to be received by the Cardholder:

a) Within 05 days from the delivery date (relying on the postal mark) for sending via correspondence; or

b) On the delivery date for sending via fax, telex or email registered by the Cardholder; or

c) On the date of announcement posted on Sacombank Cambodia official website or released to the media or posted through Sacombank Cambodia network.

11.2. The Cardholder can contact Sacombank Cambodia on +855 23 223 423 to receive answer or consultant about Card products or services (relating to the card) except for requests that are beyond Sacombank Cambodia's ability (e.g. problem caused by the Cardholder's fault upon making transaction, incident caused by the third party or another Cardholder's unreasonable requests).

## 12. EXEMPTION

12.1. The Cardholder's obligations to Sacombank Cambodia are absolute and any dispute between the Cardholder and any organisation or individual shall not affect the existing obligations of the Cardholder to Sacombank Cambodia.

12.2. Sacombank Cambodia is exempt from any responsibility or liability to the Cardholder, including any damages or loss or any harm to property, honour, prestige or reputation, arising from and/or relating to

a) Sacombank Cambodia, any Agent, ATM, POS, financial institution or any another party refusing to accept or rejecting the Card or PIN or failing to complete a transaction for any reason;

b) Any breakdown, malfunction, defect or error in any ATM, POS and/or any other equipment or Sacombank Cambodia's systems;

c) Sacombank Cambodia's delays or inability to carry out their responsibilities under this Contract caused by any breakdown or malfunction of any machine, data

processing system telecommunication service, or any industrial dispute, God of act, incident of power, error of telecommunication service supplier's transmission line, demand of the competent agent or any event beyond Sacombank Cambodia's control or consequences of any fraud or forgery;

d) Performing activities that Sacombank Cambodia considers to be appropriate to the Cardholder's instruction, even though such instructions may not have been put forward by the Cardholder;
e) Inability to access data and/or information of the Card;
f) Any transaction which is declined;
g) The delivery, quality and/or payment of any goods or services was paid by using the Card;
h) Loss of Card or the Cardholder discloses PIN and/or OTP other information and Card Transaction to any third party;
i) The Cardholder's Card Account balance is not enough for the service and/or information provided by the Cardholder is not accurate, complete or timely.
j) The Cardholder's claim is later than the deadline as regulated in the Terms and Conditions.
k) Sacombank Cambodia terminates the use of Card as regulated in the Terms and Conditions.

## 13. OTHERS

13.1. Sacombank Cambodia may, at any time, amend and supplement these Terms and Conditions by notification in advance to the Cardholder under the model stated in Clause 11. Such amendments, supplements shall bind the Cardholder if the Cardholder continues using the service after these amendments and supplements' take effect.

13.2. The Cardholder including both the Primary Cardholder and all the Supplementary Cardholders are jointly liable and responsible for their obligations under this Contract. A notice sent any Cardholder shall be deemed to be noticed to all the Cardholders.

13.3. The Cardholder authorises and consents to Sacombank Cambodia or any Sacombank Cambodia's representative to be stored, shared or exchanged any information relating to Cardholder Card, Transaction, including the Cardholder's credit information, with any other entities that Sacombank Cambdia may, at its sole discretion, consider to be appropriate.

13.4. Sacombank Cambodia has the right to assign or transfer the whole or any part of its rights and/or obligations under this Contract to any third party and the Cardholder shall do any act or accept any Sacombank Cambodia's documents in order to complete such assignment or transfer at Sacombank Cambodia's request.

13.5. The Cardholder cannot assign or transfer the whole or any part of its rights and/or obligations under this Contract to any third party.

13.6. This Contract is governed by the laws of the Kingdom of Cambodia. In the event there is any dispute between Sacombank Cambodia and the Cardholder that can not be settled by negotiation, the dispute shall be submitted to the competent court of the Kingdom of Cambodia to settle.

Sacombank

# គោលការណ៍ និងល័ក្ខខ័ណ្ឌស្តីពីការផ្តល់ និងប្រើប្រាស់ប័ណ្ណទូទាត់ បោះផ្សាយដោយធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ទៅកាន់ម្ចាស់ប័ណ្ណ

**មានប្រសិទ្ធភាពពី ០១/កក្កដា/២០១៤**

## ១. អត្ថន័យរួមៈ

អត្ថន័យខសន្យានិងលក្ខខណ្ឌខាងក្រោមរួមជាមួយនឹងការចុះឈ្មោះប្រើប្រាស់សេវាកម្មនិងកិច្ចព្រមព្រៀងបង្កើតឡើងរវាងធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី និងម្ចាស់ប័ណ្ណ (ហៅកាត់ថាកិច្ចសន្យា)។ ការចុះកិច្ចសន្យាដើម្បីទុកជាភស្តុតាងនៃលិខិតស្នើសុំចុះឈ្មោះប្រើប្រាស់សេវាកម្មធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី និងម្ចាស់ប័ណ្ណត្រូវគោរពតាមអត្ថន័យ និងលក្ខខណ្ឌទាំងឡាយ ដែលគ្រប់គ្រងការបោះផ្សាយ និងការប្រើប្រាស់ប័ណ្ណទូទាត់របស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថាប័ណ្ណ)។ ម្ចាស់ប័ណ្ណត្រូវអាន និងពិនិត្យដោយប្រុងប្រយ័ត្ននូវអត្ថន័យ និងលក្ខខណ្ឌនៃកិច្ចសន្យាមុនពេលប្រើប្រាស់ប័ណ្ណ។

## ២.ការពន្យល់អត្ថន័យពាក្យ

២.១. "ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី" គឺជាធនាគារសាយហ្គនធឿងទីន (ខេមបូឌា) ភីអិលស៊ី។

២.២. "ប័ណ្ណ" គឺជាប័ណ្ណឥណពន្ធដែលចេញដោយធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ឲ្យទៅម្ចាស់ប័ណ្ណដើម្បីធ្វើប្រតិបត្តិការលើប័ណ្ណគណនី រួមទាំងប័ណ្ណធ្វើថ្មី ឬប័ណ្ណដាក់ជំនួសណាមួយនោះ។

២.៣. "ម្ចាស់ប័ណ្ណ" គឺជាអ្នកដែលត្រូវបានចេញប័ណ្ណឲ្យដោយធនាគារ។ ម្ចាស់ប័ណ្ណ រួមមានម្ចាស់ប័ណ្ណចម្បង និង/ឬម្ចាស់ប័ណ្ណរង។

២.៤. "ម្ចាស់ចម្បង" គឺអ្នកដាក់ពាក្យស្នើសុំប័ណ្ណ និងជាអ្នកទទួលខុសត្រូវចំពោះរាល់ប្រតិបត្តិការតំលៃ កម្រៃសេវាកម្មផ្សេងៗដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ប័ណ្ណ (រួមទាំងការប្រើប្រាស់ប័ណ្ណរងផងដែរ)។

២.៥. "អ្នកប្រើប្រាស់ប័ណ្ណបន្ថែម" គឺជាអ្នកដែលត្រូវបានផ្តល់ប័ណ្ណឲ្យដោយធនាគារតាមសំណើរបស់ម្ចាស់ប័ណ្ណចម្បង និងត្រូវបានបង្ហាញតាមរយៈហត្ថលេខារបស់ម្ចាស់ប័ណ្ណចម្បងនៅលើពាក្យស្នើសុំប័ណ្ណឥណពន្ធ និងកិច្ចព្រមព្រៀងរបស់ធនាគារសាខមប៉ែង (ខេមបូឌា) ភីអិលស៊ី។

២.៦. "ពាក្យស្នើសុំ និងកិច្ចព្រមព្រៀងប័ណ្ណឥណពន្ធរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថាទម្រង់ស្នើសុំសេវាកម្ម)" គឺជាទម្រង់ដែលចេញដោយធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី និងចុះហត្ថលេខា ដោយម្ចាស់ប័ណ្ណ ដើម្បីស្នើសុំធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ពិនិត្យចេញប័ណ្ណ។

២.៧. "អេធីអឹម" គឺជាម៉ាស៊ីនទទួលប័ណ្ណស្វ័យប្រវត្តិ ឬម៉ាស៊ីនប្រតិបត្តិការប័ណ្ណដែលជាកម្មសិទ្ធិរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ឬអង្គភាពណាមួយផ្សេងទៀតដែលត្រូវបានផ្តល់សិទ្ធិក្នុងការទទួលប័ណ្ណ និងអនុញ្ញាតឲ្យម្ចាស់ប័ណ្ណ ប្រតិបត្តិការប័ណ្ណទៀងទាត់ណាមួយ។

២.៨. "លេខប័ណ្ណ" គឺជាលេខ ១៦ខ្ទង់ ដែលបានបោះពុម្ពនៅលើប័ណ្ណ។ ម្ចាស់ប័ណ្ណអាចប្រើលេខប័ណ្ណនេះដើម្បីអនុវត្ត ប្រតិបត្តិការលើប័ណ្ណណាមួយ។

២.៩. "គណនីប័ណ្ណ ឬលេខគណនីប័ណ្ណ" គឺជាលេខ ១២ខ្ទង់ ដែលបានបោះពុម្ពនៅលើប័ណ្ណ ឬនៅលើលិខិតភ្ជាប់ប័ណ្ណ។ លេខគណនីប័ណ្ណ ក៏ជាលេខគណនីប្រាក់បញ្ញើទូទាត់គ្មានកាលកំណត់របស់ម្ចាស់ប័ណ្ណចម្បងដែលបានបើកនៅធនាគារសាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ដែលតាមរយៈនេះ ប្រតិបត្តិការត្រូវបានដោះស្រាយ។

២.១០."ប្រតិបត្តិការប័ណ្ណ" គឺជាការចំណាយណាមួយដែលបានធ្វើឡើង ឬការទូទាត់ទំនិញ សេវាកម្ម ការដកប្រាក់ ការផ្ទេរប្រាក់ ការបញ្ចូលទឹកប្រាក់ និង/ឬប្រតិបត្តិការទាំងឡាយណាដែលត្រូវបានធ្វើឡើងដោយការប្រើប្រាស់ប័ណ្ណនៅតាមម៉ាស៊ីន ឬភ្នាក់ងារទទួលប័ណ្ណតាមបណ្តាទីតាំងទទួលការទូទាត់ប័ណ្ណរួមជាមួយលេខសម្ងាត់ និង/ឬលេខសម្ងាត់ប្រើតែម្តង និង/ឬ ហត្ថលេខា ឬតាមរបៀបណាមួយផ្សេងទៀត។

២.១១."ប្រតិបត្តិការតាមអ៊ីនធឺណែត" គឺជាការប្រើប្រាស់ប័ណ្ណដើម្បីទូទាត់ថ្លៃទំនិញ និងសេវាកម្មនៅលើគេហទំព័រអ៊ីនធឺណែតរបស់ស្ថាប័នទទួលការទូទាត់ប័ណ្ណ។

២.១២."ស្ថាប័នទទួលការទូទាត់ប័ណ្ណ" (ហៅកាត់ថាស្ថាប័ន) គឺអង្គភាព ឬបុគ្គល ឯកជនណាមួយដែលត្រូវបានផ្តល់សិទ្ធិដើម្បីទទួលការទូទាត់ដោយប័ណ្ណ និងអនុញ្ញាតឲ្យម្ចាស់ប័ណ្ណធ្វើប្រតិបត្តិការប័ណ្ណទៀងទាត់មួយ។

២.១៣."លេខសម្ងាត់" ជាលេខកូដសម្ងាត់ និង/ឬ អក្សរដែលចេញដោយធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ឲ្យទៅម្ចាស់ប័ណ្ណ ទាក់ទងទៅនឹងប័ណ្ណដែលតម្រូវឲ្យធ្វើប្រតិបត្តិការទៀងទាត់មួយ នៅតាមម៉ាស៊ីនអេធីអឹម ឬម៉ាស៊ីន ឆូតប័ណ្ណ។

២.១៤."OTP (លេខសម្ងាត់ប្រើតែម្តង)" គឺជាសំណុំលេខកូដសម្ងាត់ត្រូវបានចេញដោយធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ឲ្យទៅម្ចាស់ប័ណ្ណតាមរយៈមធ្យោបាយថាភូត (ដូចជាតាមទូរស័ព្ទចល័ត ឧបករណ៍ផ្ទៀងផ្ទាត់...) ដែលតម្រូវឲ្យ អនុម័តយល់ព្រមចំពោះប្រតិបត្តិការប័ណ្ណតាមប្រព័ន្ធអ៊ីនធឺណែត។

២.១៥."POS" ជាឧបករណ៍ដែលត្រូវបានប្រើប្រាស់ដោយស្ថាប័នធ្វើប្រតិបត្តិការប័ណ្ណទៀងទាត់មួយ។

## ៣.ការការពារប័ណ្ណ-លេខសម្ងាត់-លេខសម្ងាត់ប្រើតែម្តង

៣.១. ប័ណ្ណគឺជាទ្រព្យសម្បត្តិផ្តាច់មុខរបស់ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី។ ម្ចាស់ប័ណ្ណ មិនត្រូវផ្ទេរប័ណ្ណទៅឲ្យអ្នកផ្សេងឡើយ ហើយត្រូវរក្សាទុកប័ណ្ណនេះឲ្យបានល្អជានិច្ច។

៣.២. មានតែម្ចាស់ប័ណ្ណទេដែលប្រើប្រាស់ប័ណ្ណ លេខសម្ងាត់ និងលេខសម្ងាត់ប្រើតែម្តងរបស់ខ្លួន តម្រូវឲ្យប្រតិបត្តិការប័ណ្ណ។

៣.៣. លេខសម្ងាត់ និង/ឬ លេខសម្ងាត់ប្រើតែម្តង ត្រូវបានចេញដោយធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី ឲ្យទៅម្ចាស់ប័ណ្ណប្រើប្រាស់ដែលមិនអាចផ្ទេរ ហើយត្រូវរក្សាទុកប័ណ្ណ និងលេខសម្ងាត់ឲ្យបានល្អបំផុត និងមិនត្រូវ អនុញ្ញាតឲ្យនរណាម្នាក់ផ្សេងទៀតស្គាល់ជាដាច់ខាត ទោះបីដោយស្ម័គ្រចិត្តក្តី ឬមិនស្ម័គ្រចិត្តក្តី។ ការប្រើប្រាស់ប័ណ្ណណាមួយជាមួយលេខសម្ងាត់ និង/ឬ លេខសម្ងាត់ប្រើតែម្តង ដែលធ្វើឡើងដោយម្ចាស់ប័ណ្ណ ឬបុគ្គលណាក៏ដោយ ក៏ត្រូវបានចាត់ទុកថាជាការប្រើប្រាស់ដោយម្ចាស់ប័ណ្ណ។ ម្ចាស់ប័ណ្ណ ត្រូវទទួលខុសត្រូវចំពោះការអនុវត្ត កាតព្វកិច្ចណាមួយ និងទទួលរងនូវការខាតបង់ទាំងឡាយណាដែលកើតឡើងដោយប្រតិបត្តិការនោះ។

៣.៤. ម្ចាស់ប័ណ្ណ មិនត្រូវប្រើប្រាស់ប័ណ្ណ ឬអនុញ្ញាតឲ្យអ្នកដទៃទៀតប្រើប្រាស់ប័ណ្ណ ហើយត្រូវសងត្រឡប់មកវិញនូវប័ណ្ណ ដែលត្រូវបានកាត់ពាក់កណ្តាលចោល ក្រោយពេលមានស្ថានការណ៍ណាមួយក្នុងចំណោមស្ថានការណ៍ខាងក្រោមនេះ ៖

(ក) ប័ណ្ណត្រូវបានផ្លាស់ប្តូរ ប័ណ្ណខូច

(ខ) ការប្រើប្រាស់ប័ណ្ណត្រូវបានបញ្ឈប់ យោងតាមបញ្ញត្តិ និងលក្ខខណ្ឌនេះ

(គ) ម្ចាស់ប័ណ្ណ ត្រូវបានរាយការណ៍ថា ប័ណ្ណត្រូវបានបាត់ ឬចោរលួច

(ឃ) រយៈពេលសុពលភាពបញ្ជាក់លើប័ណ្ណ (ប្រសិនបើមាន) ហួសកាលបរិច្ឆេទកំណត់

លក្ខណៈនៃការប្រើប្រាស់ប័ណ្ណណាដែលកើតឡើងក្រោយពេលកើតមានស្ថានការណ៍ខាងលើ ត្រូវចាត់ទុកជាទង្វើខុសច្បាប់ ។ ម្ចាស់ប័ណ្ណត្រូវសងមកធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី រាល់ការខាតបង់ទាំងឡាយណាដែលម្ចាស់ប័ណ្ណមិនអនុវត្តឲ្យបានត្រឹមត្រូវតាមបញ្ញត្តិនិងលក្ខខណ្ឌខាងលើនេះ។

## ៤.គណនី និងប្រតិបត្តិការប័ណ្ណ

៤.១. ម្ចាស់ប័ណ្ណ ផ្ទេរសិទ្ធិជូនធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី ដោយមិនលុបចោល និងដោយគ្មានលក្ខខណ្ឌ ក្នុងការកាត់ទុក ការផ្ទេរ ឬការឃាត់ទុកទឹកប្រាក់ក្នុងគណនីប័ណ្ណ ឬគណនីទាំងឡាយណាជារបស់ម្ចាស់ប័ណ្ណដែលបានបើកនៅធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី (ប្រសិនបើសមតុល្យគណនីប័ណ្ណមិនមានគ្រប់គ្រាន់ក្នុងការទូទាត់ នូវកាតព្វកិច្ចហិរញ្ញវត្ថុរបស់ម្ចាស់ប័ណ្ណ ចំពោះធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី ដោយមិនចាំបាច់ជូនដំណឹងពីការស្នើសុំ យល់ព្រមពីម្ចាស់ប័ណ្ណឡើយ ក្នុងការកាត់យកនូវបំណុលដែលហួសពេលទូទាត់ ម្ចាស់ប័ណ្ណត្រូវទូទាត់តាមបញ្ញត្តិនៃកិច្ចសន្យា រួមទាំងកាតព្វកិច្ចហិរញ្ញវត្ថុទាំងឡាយណាទាក់ទងនឹងការប្រើប្រាស់ប័ណ្ណដែលបានបញ្ចប់ការប្រើប្រាស់ និង/ឬ បិទគណនីប័ណ្ណ។

៤.២. ប្រសិនបើម្ចាស់ប័ណ្ណ ប្រើប្រាស់ប័ណ្ណ លេខសម្ងាត់ និង/ឬលេខសម្ងាត់ប្រើតែម្តងដើម្បីធ្វើការបំរុងទុក ឬការរក្សាទុក សិទ្ធិអាទិភាពនៅក្នុងប្រតិបត្តិការណាមួយជាមួយស្ថាប័នទទួលការទូទាត់ប័ណ្ណ ហើយក្រោយមកបែរជាមិនប្រើប្រាស់សេវាកម្មរបស់ស្ថាប័ននេះ នោះម្ចាស់ប័ណ្ណ ត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះមុខស្ថាប័ន ទទួលការទូទាត់រាល់ការ ចំណាយផ្សេងៗ ចំពោះការបំរុងទុក ឬការរក្សាទុកសិទ្ធិអាទិភាពនោះស្របតាមបញ្ញត្តិនៃស្ថាប័នទទួលការទូទាត់ ។

៤.៣. ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី មានសិទ្ធិក្នុងការកាត់ទុករាល់តម្លៃនៃប្រតិបត្តិការដែលកើតពីការ ប្រើប្រាស់ប័ណ្ណ ទោះបីទំនិញនោះមិនបានផ្តល់ ឬការខ្វះចន្លោះ ឬក៏មិនអាចប្រើប្រាស់បាននូវទំនិញ ឬសេវាកម្មក៏ដោយ ម្ចាស់ប័ណ្ណត្រូវទទួលខុសត្រូវក្នុងការតវ៉ាដោយខ្លួនឯង ឬដោះស្រាយបញ្ហាណាមួយជាមួយអ្នកផ្គត់ផ្គង់អេធីអឹម ដែលអាច អនុវត្តបាន ឬស្ថាប័នទទួលការទូទាត់ពាក់ព័ន្ធនឹងការតវ៉ា ឬវិវាទនោះ។

៤.៤. រាល់ប្រតិបត្តិការ និងការចំណាយផ្សេងៗដែលត្រូវបានទូទាត់ដោយរូបិយប័ណ្ណខុសពីគណនីប័ណ្ណ នោះនឹងត្រូវបានប្តូរដោយស្វ័យប្រវត្តិទៅរូបិយប័ណ្ណរបស់គណនីប័ណ្ណភ្លាមៗនៅចំណុចប្រើប្រាស់ និងអត្រាតម្លៃដែលត្រូវបញ្ចប់ដោយប្រុងប្រយ័ត្នបំផុតរបស់ធនាគារសាខមប៊ែង (ខេមបូឌា) ភីអិលស៊ី ហើយត្រូវបានកាត់ចេញពីគណនីប័ណ្ណ។

៤.៥. ម្ចាស់ប័ណ្ណត្រូវធានាថាមានប្រាក់គ្រប់គ្រាន់ក្នុងគណនីទូទាត់គ្រប់ប្រតិបត្តិការថ្លៃសេវាដែលពាក់ព័ន្ធដល់ប័ណ្ណ ។ ក្នុងករណីខ្លះ ធនាគារសាខមប៊ែង (ខេមបូឌា) ភីអិលស៊ី មានសិទ្ធិអនុវត្តដោយមិនចាំបាច់ជូនដំណឹងជាមុន ឬផ្តល់ហេតុផល ដល់ម្ចាស់ប័ណ្ណដូចខាងក្រោម៖

ក. យល់ព្រមផ្តល់សិទ្ធិ ឬអនុញ្ញាតឲ្យរាល់ប្រតិបត្តិការថ្លៃសេវា ម្ចាស់ប័ណ្ណត្រូវតែទទួលរ៉ាប់រង ទោះបីមានប្រាក់មិនគ្រប់គ្រាន់ក្នុងគណនីប័ណ្ណក៏ដោយ

ខ. បដិសេធមិនទទួលយក មិនផ្តល់សិទ្ធិ និង/ឬ អនុញ្ញាតឲ្យប្រតិបត្តិគ្រប់ប្រតិបត្តិការថ្លៃសេវាកម្មឲ្យមានប្រសិទ្ធភាព ទោះបីមានប្រាក់គ្រប់គ្រាន់ក្នុងគណនីក៏ដោយ។

៤.៦. ក្នុងករណីប្រតិបត្តិការប័ណ្ណថ្លៃសេវា ឬចំណាយដែលព្រៀងទុកសម្រាប់ប្រតិបត្តិការឲ្យមានប្រសិទ្ធភាព ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី នឹងធ្វើការបង្កក់ទឹកប្រាក់ទុកក្នុងគណនីប័ណ្ណ នូវប្រាក់មួយចំនួនតាមការសម្រេច គិតទុករបស់ធនាគារនូវចំនួនទឹកប្រាក់ដែលបានប៉ាន់ស្មានទុកជាមុនលើតម្លៃប្រតិបត្តិការប័ណ្ណដែលបានធ្វើឡើង។ ទឹកប្រាក់ដែលបានបង្កក់ទុក នឹងត្រូវបានកាត់ទុក ឬបើកឲ្យប្រើប្រាស់ទៅតាមការ

សម្រេចចិត្តរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ហើយទឹកប្រាក់ដែលកាត់ទុកនោះ អាចមិនមែនជាចំនួនពិតប្រាកដត្រឹមត្រូវទៅនឹងប្រតិបត្តិការតម្លៃឬការចំណាយដែលត្រូវបានចាត់ទុកចុងក្រោយទៅនឹងគណនីប័ណ្ណ។

៤.៧. ម្ចាស់ប័ណ្ណ មិនត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិការប័ណ្ណមួយចំនួនដែលតាមបទបញ្ញារបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី តាមដំណាក់កាលនីមួយៗ។

## ៥.ការសន្យារបស់ម្ចាស់ប័ណ្ណ

៥.១. ម្ចាស់ប័ណ្ណ ត្រូវចុះហត្ថលេខាភ្លាមៗ នៅពេលដែលទទួលប័ណ្ណ

៥.២. ម្ចាស់ប័ណ្ណ សន្យាបង្ហាញលិខិតយថាភូតសំគាល់ខ្លួន និងផ្តល់ព័ត៌មានច្បាស់លាស់ គ្រប់គ្រាន់ ទាន់ពេលវេលាចាំបាច់តាមសំណូមពររបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ដើម្បីអនុវត្តប្រតិបត្តិការប័ណ្ណ ការត្រួតពិនិត្យទិន្នន័យ ការដោះស្រាយវាល់វិវាទ ឬបណ្ដឹងតវ៉ាដែលពាក់ព័ន្ធប្រតិបត្តិការប័ណ្ណ។ ព័ត៌មានដែលផ្តល់ពីម្ចាស់ប័ណ្ណដែលធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី មិនឲ្យប្រើតាមរយៈសារអេឡិចត្រូនិច ឬទូរស័ព្ទឡើយ ។

៥.៣. ម្ចាស់ប័ណ្ណ ព្រមព្រៀងមិនអនុវត្ត ឬអនុញ្ញាតឲ្យបុគ្គលប្រតិបត្តិការប័ណ្ណក្នុងទិសដៅផ្ទុយពីច្បាប់ ឬផ្ទុយពីកិច្ចព្រមព្រៀងប្រើប្រាស់ប័ណ្ណ។

៥.៤. ក្នុងករណីម្ចាស់ប័ណ្ណ ប្រតិបត្តិករណីប័ណ្ណលើសពីសមតុល្យ ទោះបីមូលហេតុណាក៏ដោយនោះ ម្ចាស់ប័ណ្ណត្រូវសងត្រឡប់មកធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ភ្លាមៗនូវចំនួនប្រាក់ដែលប្រើប្រាស់លើសសមតុល្យ ទោះបី ទទួលបានការជូនដំណឹងស្នើសុំ ឬមិនស្នើសុំ និងត្រូវបង់ការប្រាក់លើទឹកប្រាក់ដែលបានប្រើប្រាស់ ដែលស្មើនឹងអត្រា ការប្រាក់ ១៥០% នៃកំរិតការប្រាក់ប័ណ្ណឥណទានរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី នៅពេលដែល ប្រើប្រាស់លើសសមតុល្យ (ការប្រាក់ នឹងត្រូវបានគិតបញ្ចូលពីពេលដែលប្រើលើសសមតុល្យដែលមានរហូតដល់ពេល សងត្រឡប់គ្រប់គ្រាន់។

## ៦.សិទ្ធិ និងការទទួលខុសត្រូវរបស់ម្ចាស់ប័ណ្ណ

៦.១. នៅពេលប័ណ្ណបានបាត់ លួច ឬត្រូវខូចខាតលេខសម្ងាត់ និង/ឬ លេខសម្ងាត់ប្រើតែម្តង ត្រូវបានបែកធ្លាយព័ត៌មាន។

ក. ម្ចាស់ប័ណ្ណ ត្រូវជូនដំណឹងភ្លាមៗតាមរយៈទូរស័ព្ទមកធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី និងម្ចាស់ប័ណ្ណត្រូវមកជួបធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ដោយផ្ទាល់ដើម្បីបញ្ជាក់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬផ្ញើ ឯកសារជូនដំណឹងតាមផ្លូវច្បាប់ដល់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ក្នុងរយៈពេល១២ម៉ោង ចាប់រាប់ពីពេលបានជូនដំណឹង។

ខ. ម្ចាស់ប័ណ្ណ អាចស្នើសុំឲ្យធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ផ្តល់ជូនប័ណ្ណ និង/ឬលេខសម្ងាត់ប្រើតែម្តង ចេញប័ណ្ណជំនួស និង/ឬលេខសម្ងាត់ប្រើតែម្តង។

៦.២. ម្ចាស់ប័ណ្ណ បន្តការទទួលខុសត្រូវចំពោះប្រតិបត្តិការប័ណ្ណ (រួមទាំងការខូចខាត ការបាត់បង់ដែលកើតចេញពីប្រតិបត្តិការប័ណ្ណ) ដែលត្រូវបានធ្វើឡើងមុនពេលជូនដំណឹងជាលាយលក្ខណ៍អក្សររបស់ម្ចាស់ប័ណ្ណចំពោះការបាត់បង់ ចោរលួច ឬធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ពីការបាត់បង់ ឬវង្គ្រោះដែលកើតមានពីការផ្តល់ជូនប័ណ្ណ និងការប្រើប្រាស់ ប័ណ្ណ និងលេខសម្ងាត់ និង/ឬលេខសម្ងាត់ប្រើតែម្តងដែលបានបែកធ្លាយព័ត៌មាន ត្រូវបានបញ្ជាក់ដោយធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ថាតើប្រតិបត្តិការប័ណ្ណនេះ ត្រូវបាន ឬមិនត្រូវបានផ្តល់សិទ្ធិ។

៦.៣. ម្ចាស់ប័ណ្ណ សងធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី នូវរាល់ការបាត់បង់ ឬការខូចខាតដែលទទួលរងដោយធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ដែលទាក់ទងជាមួយ ឬកើតចេញពីការចេញ ឬការប្រើប្រាស់ប័ណ្ណ និងលេខសម្ងាត់ និង/ឬ លេខសម្ងាត់ប្រើតែម្តង។

៦.៤. ម្ចាស់ប័ណ្ណ ត្រូវផ្តល់ព័ត៌មានភ្លាមៗជាលាយលក្ខណ៍អក្សរស្តីពី (ក) ការផ្លាស់ប្តូរណាមួយចំពោះព័ត៌មានរបស់ម្ចាស់ ប័ណ្ណរួមបញ្ចូលទាំងការផ្លាស់ប្តូរអាសយដ្ឋាន និង/ឬទំនាក់ទំនងលំអិតផ្សេងទៀត និង/ឬ (ខ) ព័ត៌មានណាមួយផ្សេងទៀតរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី អាចសំណូមពរពីពេលមួយទៅពេលមួយទៀត។

៦.៥. ម្ចាស់ប័ណ្ណ ត្រូវអនុវត្តស្របតាមនីតិវិធី ដំណើរការ និងការណែនាំផ្សេងទៀតពីធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី។

៦.៦. ម្ចាស់ប័ណ្ណ ត្រូវទទួលរ៉ាប់រងនូវការខូចខាតទាំងអស់ (ប្រសិនបើមាន) ចំពោះប្រតិបត្តិការប័ណ្ណដែលកើតចេញពីកំហុស ការធ្វេសប្រហែស ឬប្រតិបត្តិការប័ណ្ណត្រូវបានរំលោភបំពានដោយបុគ្គលផ្សេងទៀត។

៦.៧. ម្ចាស់ប័ណ្ណ អាចស្នើសុំការកាត់ចំណាយសេវាកម្មត្រឡប់មកវិញចំពោះប្រតិបត្តិការប័ណ្ណមិនត្រឹមត្រូវដែលកើតចេញពីកំហុសរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ក្នុងរយៈពេល ៦០ថ្ងៃ ចាប់ពីថ្ងៃប្រតិបត្តិការប័ណ្ណបានកើតឡើង តាមរយៈការប្រើប្រាស់ប័ណ្ណនៅទូអេធីអឹម ឬម៉ាស៊ីនឆូតប័ណ្ណ បណ្តាញអ៊ីនធឺណែត។ ក្រោយរយៈពេលនេះ សំណើរបស់ម្ចាស់ប័ណ្ណនឹងមិនត្រូវបានពិចារណាឡើយ។

## ៧.សិទ្ធិ និងកាតព្វកិច្ចរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី

៧.១. ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី មានសិទ្ធិធ្វើសេចក្តីសម្រេចដោយខ្លួនឯងផ្ទាល់គ្រប់ពេលដោយមិនចាំបាច់ ជូនដំណឹងជាមុន ឬផ្តល់ជូនហេតុផលដល់ម្ចាស់ប័ណ្ណ៖

(១) បំពេញបន្ថែម កែប្រែថ្ងៃអស់សុពលភាព និង/ឬ សេចក្តីលំអិតផ្សេងទៀតនៃប័ណ្ណដែលផ្តល់ជូន ឬផ្លាស់ប្តូរប័ណ្ណ (២) សំណើរបស់ម្ចាស់ប័ណ្ណដើម្បីផ្លាស់ប្តូរលេខសម្ងាត់ដែលបង្កើតដោយម្ចាស់ប័ណ្ណ (៣) ដាក់កំរិត ព្យួរ ឬបញ្ចប់ការប្រើប្រាស់ គ្រប់សេវាកម្ម ការបង្កលក្ខណៈងាយស្រួលពាក់ព័ន្ធដល់ប័ណ្ណ និង/ឬ ប្រតិបត្តិការប័ណ្ណ។

៧.២. ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី មានសិទ្ធិ (តែមិនមានកាតព្វកិច្ច) អនុវត្តវិធីសាស្រ្តចាំបាច់រួមទាំងការការពារ ឬបដិសេធប្រតិបត្តិការប័ណ្ណ ដោយគ្មានការជូនដំណឹងមុនទៅម្ចាស់ប័ណ្ណ ក្នុងករណីខាងក្រោម៖

ក. ប្រតិបត្តិការប័ណ្ណដែលប្រតិបត្តិដោយមិនមានម្ចាស់ប័ណ្ណ។

ខ. ដើម្បីការពារការលាងសំអាតសាច់ប្រាក់ស្របទៅតាមច្បាប់។

គ. សាច់ប្រាក់នៅក្នុងគណនីប័ណ្ណរបស់ម្ចាស់ប័ណ្ណនៅធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី ត្រូវបានប្តឹងតវ៉ា។ ការប្តឹងតវ៉ានោះត្រូវផ្អែកលើហេតុផលផ្លូវច្បាប់។

ឃ. ស្របតាមសំណូមពរអាជ្ញាធរមានសមត្ថកិច្ច។

ង. ទប់ស្កាត់រាល់ការខាតបង់ដែលកើតមានចំពោះធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី និង/ឬម្ចាស់ប័ណ្ណ។

ច. ប្រតិបត្តិការផ្ទុយនឹងច្បាប់ ឬផ្ទុយកិច្ចព្រមព្រៀងប្រើប្រាស់ប័ណ្ណ។ ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី នឹងជូនដំណឹងទៅម្ចាស់ប័ណ្ណភ្លាមៗ ក្រោយពេលអនុវត្តវិធីសាស្រ្ត។

៧.៣ ភ្លាមៗក្រោយពេលទទួលបានការជូនដំណឹងរបស់ម្ចាស់ប័ណ្ណតាមបញ្ញត្តិនៃខទី ៦.១.ក ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី នឹងផ្អាកជាបណ្តោះអាសន្ននូវការប្រើប្រាស់ប័ណ្ណរបស់ម្ចាស់ប័ណ្ណរហូតដល់ពេលម្ចាស់ប័ណ្ណមកធនាគារសាខមប៊ែង (ខេមបូឌា) ភីអិលស៊ី ដោយផ្ទាល់ស្នើសុំបើកប័ណ្ណបន្តការប្រើប្រាស់ ឬរហូតដល់ម្ចាស់ប័ណ្ណបានទទួល ការផ្លាស់ប្តូរប័ណ្ណ។

៧.៤ ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី នឹងទទួលខុសត្រូវរាល់ការខូចខាតដែលកើតចេញពីការប្រើប្រាស់ប័ណ្ណ ដើម្បីដកប្រាក់នៅទូអេធីអឹម រួមបញ្ចូលទាំងមិនកំណត់ពីម្ចាស់ប័ណ្ណ មិនទទួលបាន ឬទទួលមិនគ្រប់ចំនួននូវប្រាក់ដែលបានដកចេញ។

## ៨. ថ្លៃសេវាកម្ម

៨.១. ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី មានសិទ្ធិប្រមូលថ្លៃសេវាកម្ម និងកាត់ទុកគណនីដូចខាងក្រោម:

ក. ថ្លៃសេវាកម្មផ្តល់ប័ណ្ណៈ នៅពេលផ្តល់ប័ណ្ណ និង/ឬផ្លាស់ប្តូរប័ណ្ណថ្មី។

ខ. ថ្លៃសេវាកម្មផ្តល់ប័ណ្ណរហ័សៈ គិតថ្លៃសេវាកម្មនៅពេលម្ចាស់ប័ណ្ណស្នើសុំផ្តល់ប័ណ្ណ ឬផ្លាស់ប្តូរប័ណ្ណរហ័ស។

គ. ថ្លៃសេវាកម្មជូនដំណឹងៈ គិតថ្លៃនៅពេលចេញរបាយការណ៍ស្តីពីប្រតិបត្តិការ ផ្ញើជូនដល់ម្ចាស់ប័ណ្ណ។

ឃ. ថ្លៃសេវាកម្មប្រចាំឆ្នាំៈ ប្រមូលលើប័ណ្ណនីមួយៗក្នុងមួយឆ្នាំម្តង ឬបែងចែកជាចំនួន១២ខែស្មើគ្នា គិតជារៀងរាល់ខែ។

ង. ថ្លៃសេវាកម្មដកសាច់ប្រាក់ៈ គិតថ្លៃនៅពេលប្រើប្រាស់ប័ណ្ណដើម្បីដកសាច់ប្រាក់។

ច. ថ្លៃសេវាកម្មត្រួតពិនិត្យសមតុល្យៈ គិតថ្លៃនៅពេលប្រើប្រាស់ប័ណ្ណដើម្បីពិនិត្យសមតុល្យគណនីប័ណ្ណ។

ឆ. ថ្លៃសេវាកម្មប្តូរប័ណ្ណៈ គិតថ្លៃនៅពេលម្ចាស់ប័ណ្ណស្នើសុំប្តូរប័ណ្ណ។

ជ. ថ្លៃសេវាកម្មដែលបាត់ ឬត្រូវបានចោរលួចៈ គិតថ្លៃនៅពេលម្ចាស់ប័ណ្ណជូនដំណឹងមកធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី ពេលប័ណ្ណបាត់បង់ ឬត្រូវបានចោរលួច។

ឈ. ថ្លៃសេវាកម្មផ្តល់លេខសម្ងាត់ឡើងវិញៈ គិតថ្លៃនៅពេលដែលម្ចាស់ប័ណ្ណសំណូមពរសុំលេខសម្ងាត់ឡើងវិញ។

ញ. ថ្លៃសេវាកម្មបញ្ជាក់ប្រតិបត្តិការៈ គិតថ្លៃនៅពេលដែលម្ចាស់ប័ណ្ណស្នើសុំធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី បញ្ជាក់ជាលាយលក្ខណ៍អក្សររាល់ព័ត៌មានដែលពាក់ព័ន្ធនឹងប័ណ្ណប្រតិបត្តិការ ឬគណនីប័ណ្ណ។

ដ. ថ្លៃសេវាកម្មផ្តល់វិក័យបត្រ័ថតចម្លងនៃប្រតិបត្តិការៈ គិតថ្លៃពេលម្ចាស់ប័ណ្ណស្នើសុំវិក័យប័ត្រថតចម្លងរបស់វិក័យប័ត្រច្បាប់ដើម។

ឋ. ថ្លៃសេវាកម្មបណ្តាលមកពីការតវ៉ាខុសៈ គិតថ្លៃពេលការស្នើសុំតវ៉ារបស់ម្ចាស់ប័ណ្ណ ត្រូវបានគេរកឃើញថាមិនត្រឹមត្រូវ ឬ មិនពិតប្រាកដ។

ឌ. ថ្លៃសេវាកម្មប្រតិប្រត្តិការប្តូរប្រាក់ៈ គិតថ្លៃនៅពេលមានការប្តូរប្រាក់ពីចំនួនរូបិយប័ណ្ណបរទេសទៅតាមរូបិយប័ណ្ណ គណនី។

ធ. ថ្លៃសេវាកម្មពិសេសៈ គិតថ្លៃនៅពេលដែលម្ចាស់ប័ណ្ណស្នើសុំការងារបន្ថែម ឬពិសេសដែលត្រូវអនុវត្ត ដោយធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី យល់ព្រមប្រតិប្រត្តិការ។

ន. ថ្លៃសេវាកម្មផ្លាស់ប្តូរផលិតផលៈ គិតថ្លៃពេលដែលម្ចាស់ប័ណ្ណស្នើសុំផ្លាស់ប្តូរប្រភេទប័ណ្ណទូទាត់ផ្សេងៗនៃផលិតផលប័ណ្ណឥណពន្ធឬការបន្ថែមឬការដកចេញនៃសេវាកម្ម អត្ថប្រយោជន៍ ឬចំណុចពិសេសរបស់ប័ណ្ណ។

ប. ថ្លៃសេវាកម្មនៃភាពមិនស្មោះត្រង់ៈ គិតថ្លៃពេលដែលមានភាពមិនស្មោះត្រង់កើតឡើង ពាក់ព័ន្ធនឹងការទូទាត់ សាច់ប្រាក់ចូលទៅកាន់គណនី។

៨.២ សេចក្តីលំអិតស្តីពីថ្លៃសេវាកម្មគ្រប់ប្រភេទ ត្រូវបានសម្រេចនៅក្នុងតារាងបញ្ជាក់ពីថ្លៃសេវាកម្ម របស់ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី (កាលវិភាគសេវាកម្ម) ក្នុងការអនុវត្តន៍ទៅលើប័ណ្ណហើយកាលវិភាគសេវាកម្មផ្នែកមួយនៃលក្ខខណ្ឌរបស់កិច្ចសន្យាទាំងមូល។ នៅពេលដែលមានការផ្លាស់ប្តូរអត្រានៃថ្លៃសេវាកម្ម ប្រភេទនៃថ្លៃសេវាកម្ម និងរបៀបនៃការគិតថ្លៃសេវាកម្ម នោះម្ចាស់ប័ណ្ណនឹងទទួលបានការជូនដំណឹងស្របតាមប្រការ១១។ តារាងកាលវិភាគ សេវាកម្មថ្មី នឹងមានសុពលភាពចំពោះម្ចាស់ប័ណ្ណ ប្រសិនបើម្ចាស់ប័ណ្ណប័នប្រើបាស្រ់សេវាកម្មនៅពេលដែលតារាង កាលវិភាគសេវាកម្មថ្មីមានសុពលភាព។ តារាង

កាលវិភាគសេវាកម្មមាននៅលើគេហទំព័រ www.sacombank.com.kh ឬនៅសាខាណាមួយរបស់ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី ឬតាមរយៈទូរស័ព្ទទៅកាន់ភ្នាក់ងារបម្រើសេវា អតិថិជនរបស់ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី។

## ៩. ការបញ្ចប់ការប្រើប្រាស់ប័ណ្ណ

៩.១ ភាគីនីមួយៗ មានសិទ្ធិបញ្ចប់ជាឯកតោភាគីក្នុងកិច្ចសន្យាប្រើប្រាស់ប័ណ្ណតាមរយៈការជូនដំណឹងជាលាយល័ក្ខណ៍ អក្សរ ឲ្យភាគីម្ខាងទៀតក្នុងរយៈពេល ១០ថ្ងៃជាមុន។ ម្ចាស់ប័ណ្ណចម្បង អាចបញ្ចប់ការប្រើប្រាស់ប័ណ្ណរបស់អ្នកប្រើប្រាស់ប័ណ្ណរងបាន។ ការបញ្ចប់ការប្រើប្រាស់ប័ណ្ណចម្បង មានន័យថាជាការបញ្ចប់កិច្ចសន្យាទាំងស្រុង។ ក្នុងករណីធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី បញ្ចប់ការប្រើប្រាស់ប័ណ្ណជាឯកតោភាគី ដែលត្រូវប្រតិបត្តិតាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច ឬបណ្តាលមកពីម្ចាស់ប័ណ្ណរំលោភលើកាតព្វកិច្ចដែលអនុវត្តចំពោះធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី ដែលមិនទទួលខុសត្រូវក្នុងការជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណឡើយ។

៩.២ ក្រោយពេលបញ្ឈប់ការប្រើប្រាស់ប័ណ្ណមានសុពលភាពៈ (ក) ម្ចាស់ប័ណ្ណ ត្រូវបន្តទទួលខុសត្រូវសងប្រាក់ដែលនៅ សេសសល់ចំពោះប្រតិបត្តិការ ថ្លៃសេវាកម្ម ប្រាក់ពិន័យ និងរាល់សំណងខូចខាតណាដែលបានធ្វើឡើងមុន ឬ ក្រោយ ពេលបញ្ចប់ការប្រើប្រាស់ប័ណ្ណ (រាប់បញ្ចូលទាំងថ្លៃសេវាកម្ម និងការចំណាយដែលមិនទាន់លេចចេញក្នុងគណនីប័ណ្ណ) (ខ) រាល់ការទូទាត់ដែលមិនទាន់ដល់ពេលកំណត់តាមកិច្ចសន្យា និងត្រូវទូទាត់ភ្លាមៗដោយពុំចាំបាច់ជូនដំណឹង ឬសំណូមពរឡើយ (គ)ដូច្នេះ ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី នឹងមិនទទួលខុសត្រូវចំពោះការសងត្រលប់នូវថ្លៃសេវាកម្មណាមួយឡើយ (ឃ) ហើយកិច្ចសន្យា អត្ថន័យ និងលក្ខខណ្ឌនៃកិច្ចសន្យានៅតែមានសុពលភាពរហូតដល់ ពេលម្ចាស់ប័ណ្ណបានអនុវត្តរួចរាល់ និងគ្រប់គ្រាន់រាល់កាតព្វកិច្ចហិរញ្ញវត្ថុចំពោះធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី។

៩.៣ ក្រោយពេលបញ្ឈប់ការប្រើប្រាស់ប័ណ្ណ ហើយម្ចាស់ប័ណ្ណ បានបំពេញរាល់កាតព្វកិច្ចហិរញ្ញវត្ថុចំពោះធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី ក្នុងករណីដែលគណនីប័ណ្ណនៅសល់សមតុល្យហើយម្ចាស់ប័ណ្ណមិនមកធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី ទទួលចំនួនប្រាក់នោះធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី នឹងមានសិទ្ធិគិតថ្លៃ សេវាកម្មគ្រប់គ្រងចំពោះចំនួនសាច់ប្រាក់នោះទៅតាមបទបញ្ជារបស់ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី ពីរយៈពេលមួយ ទៅរយៈពេលមួយទៀត។

## ១០.ឯកសារយថាភូត

១០.១ ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី អាចយោងលើ (ក) គ្រប់ឯកសារប្រតិបត្តិការណាដែលពាក់ពន្ធ័ដល់ប្រតិបត្តិការការស្នើសុំ ឬសេចក្តីណែនាំដែលចុះហត្ថលេខាដោយម្ចាស់ប័ណ្ណ (ខ) រាល់ប្រតិបត្តិការណាដែលប្រើលេខ សម្ងាត់ ឬលេខសម្ងាត់ប្រើតែម្តងរបស់ម្ចាស់ប័ណ្ណ (គ) ឬ ឯកសារផ្សេងទៀតណាដែលបានប្រយោជន៍ដល់ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី មានរួមបញ្ចូលទាំងការថតសម្លេង ឬសារអេឡិចត្រូនិកដែលពាក់ពន្ធ័ដល់ម្ចាស់ប័ណ្ណ គណនីប័ណ្ណ ឬការប្រើប្រាស់ប័ណ្ណជាភស្តុតាងត្រឹមត្រូវបង្ហាញពីប្រតិបត្តិការប័ណ្ណ សំណើ និង/ឬបញ្ជាដែលត្រូវបាន ធ្វើឡើងដោយម្ចាស់ប័ណ្ណ។

១០.២ ម្ចាស់ប័ណ្ណ ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរមកធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី ចំពោះការខកខាន ការភាន់ច្រឡំកំហុស និង/ឬចម្ងល់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការប័ណ្ណ ថ្លៃសេវាកម្ម ការកាត់ ឬបញ្ចូលសាច់ប្រាក់ និង/ឬការកាត់ថ្លៃសេវាកម្មពីគណនីប័ណ្ណក្នុងរយៈពេលកំណត់១០ថ្ងៃ គិតចាប់ពីថ្ងៃកើតមានការខកខាន ការភាន់ច្រឡំកំហុស និង/ឬចម្ងល់។ ក្នុងកំឡុងពេលនេះ ប្រសិនធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី មិនទទួលបានបណ្តឹងតវ៉ា ពីម្ចាស់ប័ណ្ណ នោះចំនួនប្រាក់ដែលទទួលបន្ទុកចំពោះគណនីប័ណ្ណ នឹងក្លាយជាភស្តុតាងត្រឹមត្រូវបញ្ជាក់ថាប្រតិបត្តិការថ្លៃសេវាកម្ម ការកាត់ឬបញ្ចូលសាច់ប្រាក់ ឬការកាត់ថ្លៃសេវាកម្មជាការពិត និងមានសុពលភាព លើកលែងតែធនាគារសាខមប៊េង (ខេមបូឌា) ភីអិលស៊ី សម្រេចតាមសិទ្ធិផ្ទាល់ខ្លួនក្នុងការកែប្រែ និង/ឬបំពេញបន្ថែមរាល់ខ្ទង់ចូលទៅក្នុង គណនីប័ណ្ណនៅពេលក្រោយណាមួយនោះ។

## ១១ ជូនដំណឹង

១១.១.រាល់ការជូនដំណឹងជាលាយល័ក្ខណ៍អក្សររបស់ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី ដល់ម្ចាស់ប័ណ្ណតាម អាស័យដ្ឋានចុងក្រោយ ដែលម្ចាស់ប័ណ្ណបានចុះឈ្មោះ ឬប្រកាសនៅលើគេហទំព័រផ្លូវការរបស់ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី ឬប្រកាសតាមបណ្តាញព័ត៌មាន ឬប្រកាសតាមរយៈបណ្តាញផ្សព្វផ្សាយរបស់ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី។ ការប្រកាសផ្សាយទាំងឡាយ ត្រូវបានចាត់ទុកថាបានទទួលដោយម្ចាស់ប័ណ្ណដូចខាងក្រោមៈ

ក. ក្នុងរយៈពេល ០៥ថ្ងៃ គិតចាប់ពីថ្ងៃបានផ្ញើ (ផ្អែកតាមត្រានៃប្រៃសនីយ៍) ចំពោះការផ្ញើតាមសំបុត្រ។ ឬ

ខ. ក្នុងថ្ងៃដែលផ្ញើដោយទូរសារ ផ្ញើសារតាម Telex ឬសារអេឡិចត្រូនិកដែលម្ចាស់ប័ណ្ណបានចុះឈ្មោះ។ ឬ

គ. ក្នុងថ្ងៃដែលបានប្រកាសលើគេហទំព័រផ្លូវការរបស់ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី ឬការចេញផ្សាយ តាមបណ្តាញសារព័ត៌មាន ឬផ្សាយតាមរយៈបណ្តាញរបស់ធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី។

១១.២
ម្ចាស់ប័ណ្ណ អាចទំនាក់ទំនងជាមួយធនាគារ សាខមប៊េង (ខេមបូឌា) ភីអិលស៊ី តាមរយៈទូរស័ព្ទលេខ +៨៥៥ ២៣ ២២៣ ៤២៣ ដើម្បីឆ្លើយតប ឬប្រឹក្សាយោបល់ពីផលិតផល ឬសេវាកម្មប័ណ្ណ

(ពាក់ព័ន្ធដល់ប័ណ្ណ) លើកលែងតែរាល់សំណូមពរលើសពីសមត្ថភាពរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី (ដូចជាបញ្ហាដែលកើតឡើងដោយកំហុស របស់ម្ចាស់ប័ណ្ណ នូវធ្វើប្រតិបត្តិការ ឧប្បត្តិហេតុបណ្ដាលមកពីតតិយជន ឬសំណូមពរមិនសមហេតុផលផ្សេងទៀតរបស់ ម្ចាស់ប័ណ្ណ)។

## ១២. អញ្ញត្រកម្ម

១២.១ កាតព្វកិច្ចរបស់ម្ចាស់ប័ណ្ណចំពោះធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី គឺជាកាតព្វកិច្ចដាច់ខាត ហើយរាល់ វិវាទរវាងម្ចាស់ប័ណ្ណជាមួយនឹងស្ថាប័ន ឬបុគ្គលឯកជនណាមួយ មិនពាក់ព័ន្ធដល់កាតព្វកិច្ចដែលកំពុងអនុវត្តរបស់ម្ចាស់ប័ណ្ណ ចំពោះធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ។

១២.២ ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី រួចផុតពីបន្ទុក និងការទទួលខុសត្រូវចំពោះម្ចាស់ប័ណ្ណរួមបញ្ចូលទាំងការខាតបង់ ឬអន្តរាយចំពោះទ្រព្យសម្បត្តិ កិត្តិយស កិត្យានុភាព ឬកេរ្តិ៍សេចក្តីថ្លៃថ្នូរដែលកើតមាន និង/ឬមានពាក់ពន្ធ័ដល់:

ក. ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី កន្លែងទទួលប័ណ្ណអេធីអឹម ម៉ាស៊ីនឆូតប័ណ្ណ ស្ថាប័នហិរញ្ញវត្ថុណា ឬភាគីណាមួយផ្សេងទៀតដែលបដិសេធមិនទទួល ឬបដិសេធប័ណ្ណ ឬលេខសម្ងាត់ ឬលេខសម្ងាត់ប្រើតែម្តង ឬមិនបំពេញប្រតិបត្តិការចំពោះហេតុផលណាមួយ។

ខ. ការខូចខាត ការមិនដំណើរការ ភាពខ្វះចន្លោះ ឬកំហុសនៅក្នុងម៉ាស៊ីនអេធីអឹម ម៉ាស៊ីនឆូតប័ណ្ណណាមួយ និង/ឬ ឧបករណ៍ណាផ្សេងទៀត ឬប្រព័ន្ធរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី។

គ. ការពន្យាពេល ឬអលទ្ធភាពរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ក្នុងការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យានេះដែលបណ្ដាលមកពីការខូចខាត ការមិនដំណើរការរបស់ម៉ាស៊ីនណាមួយ បណ្ដាញដំណើរការទិន្នន័យនៃសេវាកម្មប្រព័ន្ធទូរគមនាគមន៍ ឬរាល់បញ្ហាទំនាស់ឧស្សាហកម្ម ករណីប្រធានស័ក្តិ ការខាតបង់ ឧប្បត្តិហេតុដោយសារអគ្គីសនី កំហុស ខ្សែសង្វាក់របស់សេវាផ្គត់ផ្គង់ទូរគមនាគមន៍ សំណូមពររបស់ភ្នាក់ងារមានសមត្ថកិច្ច ឬព្រឹត្តិការណ៍ដែលហួសពីការ គ្រប់គ្រងរបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ឬលទ្ធផលអាក្រក់នៃការលួចបន្លំ ឬក្លែងបន្លំណាមួយនោះ។

ឃ. ប្រតិបត្តិរាល់សកម្មភាពដែលធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ចាត់ទុកថាសមស្របជាមួយនឹងការបញ្ជារបស់ម្ចាស់ប័ណ្ណ ទោះបីរាល់ការបញ្ជានោះអាចមិនត្រូវបានលើកឡើងពីគំនិតរបស់ម្ចាស់ប័ណ្ណ។

ង. អលទ្ធភាពក្នុងដំណើរការទិន្នន័យ និង/ឬព័ត៌មានពីប័ណ្ណ។

ច. ប្រតិបត្តិការណាមួយដែលត្រូវបានបដិសេធ។

ឆ. ការផ្ទេរ គុណភាព និង/ឬការទូទាត់សំរាប់ទំនិញ ឬសេវាកម្ម ត្រូវបានធ្វើឡើងដោយការប្រើប័ណ្ណ។

ជ. ការបាត់ប័ណ្ណ ឬម្ចាស់ប័ណ្ណ បានធ្វើអោយលេចធ្លាយនូវលេខសម្ងាត់ និង/ឬលេខសម្ងាត់ប្រើតែម្តង និង/ឬព័ត៌មាន និងប្រតិបត្តិការប័ណ្ណផ្សេងទៀតដល់តតិយជនណាមួយនោះ។

ឈ. សមតុល្យក្នុងគណនីរបស់ម្ចាស់ប័ណ្ណ មិនគ្រប់គ្រាន់សំរាប់ធ្វើប្រតិបត្តិការ និង/ឬព័ត៌មានដែលផ្តល់ដោយម្ចាស់ប័ណ្ណ មិនច្បាស់លាស់ មិនគ្រប់គ្រាន់ ឬមិនទាន់ពេលវេលា។

ញ. បណ្តឹងតវ៉ារបស់ម្ចាស់ប័ណ្ណ មិនទាន់ពេលវេលាកំណត់ដូចបានបញ្ញត្តិក្នុងអត្ថន័យ និងលក្ខខណ្ឌនេះ។

ដ. ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី បញ្ចប់ការប្រើប្រាស់ប័ណ្ណដូចបានបញ្ញត្តិក្នុងអត្ថន័យ និងលក្ខខណ្ឌនេះ។

## ១៣. សេចក្តីសំរេចផ្សេងៗ

១៣.១ ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី មានសិទ្ធិកែប្រែ បំពេញបន្ថែមអត្ថន័យ និងលក្ខខណ្ឌនៅពេលណាមួយដោយជូនដំណឹងមុនទៅម្ចាស់ប័ណ្ណដូចមានចែងក្នុងប្រការទី១១។ ការកែប្រែ និងបំពេញបន្ថែមនេះ មានតម្លៃចាប់បង្ខំ ម្ចាស់ប័ណ្ណ បើម្ចាស់ប័ណ្ណបន្តប្រើបាស្រ់សេវាកម្ម ក្រោយការកែប្រែ និងការបំពេញបន្ថែមមានសុពលភាព។

១៣.២ ម្ចាស់ប័ណ្ណ ទាំងអ្នកប្រើប័ណ្ណចម្បង និងអ្នករួមប្រើប័ណ្ណទាំងអស់ ទទួលសង និងទទួលខុសត្រូវរួមគ្នាចំពោះកាតព្វកិច្ចនៃកិច្ចសន្យា។ ការជូនដំណឹងដល់ម្ចាស់ប័ណ្ណណាមួយនោះ ត្រូវបានចាត់ទុកជាការជូនដំណឹងដល់គ្រប់ម្ចាស់ប័ណ្ណ។

១៣.៣ ម្ចាស់ប័ណ្ណផ្ទេរសិទ្ធិ និងយល់ព្រមឲ្យធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ឬអ្នកតំណាងណាមួយរបស់ធនាគារសាខមប៉ែង (ខេមបូឌា) ភីអិលស៊ី រក្សាទុកចែករំលែក ឬ ផ្លាស់ប្តូរព័ត៌មានណាមួយទាក់ទងនឹងម្ចាស់ប័ណ្ណ ប្រតិបត្តិការប័ណ្ណ រួមបញ្ចូលទាំងព័ត៌មានឥណទានរបស់ម្ចាស់ប័ណ្ណជាមួយអង្គភាពណាមួយផ្សេងទៀតដែលធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី អាចពិនិត្យឲ្យសមស្របដោយខ្លួនឯងផ្ទាល់។

១៣.៤ ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី មានសិទ្ធិកំណត់ ឬប្រគល់សិទ្ធិ និង/ឬកាតព្វកិច្ចមួយផ្នែក ឬទាំងស្រុង ទៅតាមកិច្ចសន្យានេះឲ្យទៅតតិយភាគីណាមួយ ហើយម្ចាស់ប័ណ្ណត្រូវប្រតិបត្តិសកម្មភាព ឬទទួលយកឯកសារ ណាមួយ របស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ដើម្បីបំពេញចំពោះការកំណត់ ឬការផ្ទេរតាមសំណូមពររបស់ធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី ។

១៣.៥ ម្ចាស់ប័ណ្ណមិនអាចកំណត់ ឬផ្ទេរផ្នែកណាមួយ ឬទាំងស្រុងនូវសិទ្ធិ និង/ឬកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យាឲ្យទៅតតិយជនណាមួយបានឡើយ។

១៣.៦ កិច្ចសន្យានេះ ត្រូវបានគ្រប់គ្រងដោយច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីមានទំនាស់រវាងធនាគារ សាខមប៉ែង (ខេមបូឌា) ភីអិលស៊ី និងម្ចាស់ប័ណ្ណដែលមិនអាចដោះស្រាយបានដោយការចរចារបញ្ចប់វិវាទទេវិវាទនោះនឹងត្រូវបានបញ្ជូនទៅកាន់តុលាការមានសមត្ថកិច្ចនៅព្រះរាជាណាចក្រកម្ពុជាដើម្បីដោះស្រាយ។